ISSN 1560-7615 / ISBN 978-99950-52-06-5


# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២៤ លេខ ២ | ខែមិថុនា ឆ្នាំ២០២០ | តម្លៃ ១.៥០០៛


30th ANNIVERSARY CDRI 1990 - 2020

# កត្តារារាំងការសម្រេចអត្ថប្រយោជន៍បានដោយជោគជ័យនៃកម្មវិធីប្រែប្រួលអាកាសធាតុនៅកម្ពុជា៖ ករណីសិក្សានៃគម្រោងទឹកនិងអនាម័យនៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

## សេចក្តីផ្តើម

ការប្រែប្រួលអាកាសធាតុ និងភាពក្រីក្រ នៅតែបន្តចោទបញ្ហាធំធេង និងជាបន្ទាន់ដល់ប្រទេសកំពុងអភិវឌ្ឍន៍នានា។ ថ្វីបើការបោះជំហានធំៗក្នុងប៉ុន្មានទសវត្សរ៍កន្លងមក បានលើកស្ទួយប្រជាជនជាច្រើនលាននាក់ ឲ្យចាកផុតពីភាពក្រីក្រក្តី ប៉ុន្តែបើសិនពុំមានសកម្មភាពរួមគ្នាដើម្បីសម្រាលការប្រែប្រួលអាកាសធាតុនោះទេ ជោគជ័យដែលសម្រេចបាន គឺអាចបាត់បង់ទៅវិញយ៉ាងលឿន។ ការប្រមើលឃើញនេះគួរឲ្យព្រួយបារម្ភណាស់។ ការប៉ាន់ស្មានមួយចំនួននាពេលថ្មីៗ បានអះអាងថា នៅឆ្នាំ២០៣០ ការប្រែប្រួលអាកាសធាតុ អាចញាំងប្រជាជនប្រមាណ ១០០លាននាក់ ឲ្យធ្លាក់ចូលវិញក្នុងភាពក្រីក្របំផុត ហើយគ្រោះមហន្តរាយផ្នែកធាតុអាកាស អាចបង្ខំឲ្យប្រជាជនប្រមាណ ២០០លាននាក់ ត្រូវចាកចេញពីកន្លែងរស់នៅសព្វថ្ងៃ (Khoday and Ali, 2018)។ ជាចម្លើយតប រដ្ឋាភិបាល អង្គការអភិវឌ្ឍន៍អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា កំពុងពន្លឿនកម្មវិធីធ្វើអន្តរាគមន៍ផ្សេងៗនៅតាមមូលដ្ឋាន ដើម្បីកាត់បន្ថយភាពក្រីក្រ និងកសាងសមត្ថភាពបន្សាំរបស់សហគមន៍ក្នុងមូលដ្ឋាន ឲ្យចេះរៀបចំជីវភាពអាចធន់ទ្រាំបានកាន់តែប្រសើរនឹងការប្រែប្រួលអាកាសធាតុ។



ស្ទូនបន្លែតាមផ្ទះទទួលបានជោគជ័យ ក្នុងកម្មវិធីរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ធំ ខែតុលា ឆ្នាំ២០១៨

នៅតាមប្រទេសកំពុងអភិវឌ្ឍន៍នានា មានកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុកាន់តែច្រើនឡើង ផ្តោតលើការកសាងភាពធន់របស់ ក្រុមងាយរងគ្រោះនៅតាមមូលដ្ឋានដែលមានជាអាទិ៍ ជនក្រីក្រ គ្រួសារមានស្ត្រីជាមេគ្រួ មនុស្សចាស់ ជនពិការ និងកុមារ។ ក្រុមងាយរងគ្រោះអាចពិបាកជួយ ឬឈោងដល់ណាស់ ទោះបីមានអន្តរាគមន៍ដែលគេបានធ្វើផែនការយ៉ាងល្អ និងអនុវត្តចំចំណុចក្តី។ របាំងចម្បងៗរារាំងការសម្រេចបានអត្ថប្រយោជន៍ដោយជោគជ័យ រួមមាន ប្រព័ន្ធស្រោចស្រពនិងរំដោះទឹកមិនគ្រប់គ្រាន់ ជំនាញនិងការអប់រំកម្រិតទាប ការមិនមានប្រភពទឹកប្រើប្រាស់ អសន្តិសុខស្បៀង កង្វះចំណាប់អារម្មណ៍និងការអប់រំពីការប្រែប្រួលអាកាសធាតុ ដែលនាំឲ្យខ្វះខាតភាពត្រៀមទប់ទល់នឹងគ្រោះមហន្តរាយ (ការរាំងស្ងួត ទឹកជំនន់) កង្វះបណ្តាញនិងការចែករំលែកព័ត៌មាន ការវិវត្តក្នុងកម្មសិទ្ធិដីធ្លីនិងភាពគ្មានដីធ្លី លទ្ធភាពមានតិច ឬគ្មានសោះ ដើម្បីទទួលបានធនធាន និងសេវាហិរញ្ញវត្ថុ (Nang and Ouch 2014; Nyahunda and Tirivangasi 2019)។

---

អត្ថបទនេះរៀបរៀងដោយ បណ្ឌិត លន់ ពេជ្រតារា អ្នកស្រាវជ្រាវ និងជានាយកមជ្ឈមណ្ឌល, នង មុនិន្ទ អ្នកស្រាវជ្រាវ, ឆាំង ម៉ារ៉ុង ជំនួយការស្រាវជ្រាវ, ឌួង ស៊ីវមុយ ជំនួយការស្រាវជ្រាវ, នៃមជ្ឈមណ្ឌលធនធានធម្មជាតិ និងបរិស្ថាន។ សូមយោងអត្ថបទនេះថា៖ Lonn Pichdara, Nong Monin, Chhaing Marong and Duong Sivmuy. 2020. "Factors Hindering Successful Benefits Realisation of Cambodia's Climate Change Program: Case Study of a Water and Sanitation Project, Kampong Svay District, Kampong Thom Province." *Cambodia Development Review* 24 (1): 1–6.

## មាតិកា


កត្តារារាំងការសម្រេចអត្ថប្រយោជន៍បានដោយជោគជ័យ នៃកម្មវិធីប្រែប្រួលអាកាសធាតុនៅកម្ពុជា ........................ ១
ការចុះកម្មសិក្សានៅក្រៅប្រទេស៖ ករណីសិក្សាពី និស្សិតកូរ៉េនៅកម្ពុជា ........................ ៦
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........................ ១០
— ស្ថានភាពក្នុងប្រទេស ........................ ១៣
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........................ ២៤

កម្ពុជា ស្ថិតក្នុងចំណោមប្រទេស ត្រូវប៉ះពាល់ខ្លាំងជាងគេដោយសារគ្រោះធម្មជាតិ និងតែងរងគ្រោះ សឹងតែជាលក្ខណៈរដូវកាលដោយទឹកជំនន់ ការរាំងស្ងួត និងខ្យល់ព្យុះ។ ភាពងាយរងគ្រោះនេះ កាន់តែធ្ងន់ធ្ងរឡើងដោយសារប្រជាជន ៧៧% ក្នុងនេះមានទាំងជនក្រីក្រភាគច្រើនផង កំពុងរស់នៅក្នុងតំបន់ជនបទ និងពឹងផ្អែកកម្រិតខ្ពស់លើ កសិកម្មស្រោចស្រពដោយទឹកភ្លៀង (ភាគច្រើនស្រូវ) ដើម្បីបានស្បៀងអាហារ និងប្រាក់ចំណូល (Yusuf and Francisco 2009; NIS 2019)។ ខេត្តកំពង់ធំដែលនៅជាប់បឹងទន្លេសាប ក្នុងតំបន់កណ្ដាលប្រទេសកម្ពុជា ស្ថិតក្នុងចំណោមខេត្តក្រីក្រ និងតែងប៉ះពាល់ខ្លាំងជាងគេដោយទឹកជំនន់ និងការរាំងស្ងួត។ គ្រោះធម្មជាតិដែលកើតមានជារឿយៗទាំងនេះ តែងបង្កការខូតខាតធ្ងន់ធ្ងរ ជាពិសេសទៅលើប្រភពទឹក និងប្រព័ន្ធអនាម័យដែលមិនទាន់បានកែលំអ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទិន្នផលដំណាំ ផលិតកម្មសត្វចិញ្ចឹម ហើយអាចប៉ះពាល់ដល់ជីវិតមនុស្សទៀតផង (NCDM 2020)។

នៅខេត្តកំពង់ធំ ស្រុកកំពង់ស្វាយតែងងាយរងគ្រោះដោយការរាំងស្ងួត។ ជាចម្លើយតប ក្រសួងអភិវឌ្ឍន៍ជនបទ ដោយមានជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពី សម្ព័ន្ធកម្ពុជានៃការប្រែប្រួលអាកាសធាតុ (CCCA) និង អង្គការការីតាសកម្ពុជា បានអនុវត្តកម្មវិធីសាកល្បងមួយ (ដែលមានទាំងគម្រោងតូចៗជាច្រើនផង) នៅតាមឃុំតែងប៉ះពាល់ខ្លាំងជាងគេ ដើម្បីកែលំអប្រព័ន្ធផ្គត់ផ្គង់ទឹកនិងអនាម័យខ្នាតតូច និងសន្តិសុខស្បៀង នៅរដូវប្រាំង ហើយជាពិសេសដើម្បី ពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុនៃហេដ្ឋារចនាសម្ព័ន្ធផ្អែកទឹក (អណ្ដូង ប្រព័ន្ធប្រមូលនិងស្ដុកទឹកភ្លៀង) និង កសាងបង្គន់អនាម័យ និងសួនបន្លែតាមផ្ទះ។

អត្ថបទនេះ ផ្អែកលើការសិក្សាបែបគុណវិស័យមួយដើម្បីវាយតម្លៃពីផលប៉ះពាល់ នៃបណ្ដាកម្មវិធីស្ដីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា រួមទាំង កម្មវិធីសាកល្បងនៅស្រុកកំពង់ស្វាយ របស់ក្រសួងអភិវឌ្ឍន៍ជនបទផង (CDRI, MRD and UNDP 2019)។ អត្ថបទនេះរៀបរាប់ដោយសង្ខេបនូវ បទពិសោធន៍សំខាន់ៗដែលរៀនសូត្របាន និងធ្វើការពិភាក្សាពីកត្តាចម្បងៗដែលរារាំងជនក្រីក្រ និងជនងាយរងគ្រោះ បានទទួលផលពីកម្មវិធីជំនួយក្នុងការអនុវត្តតាមសកម្មភាពគាត់បានឃើញគេធ្វើបង្ហាញ ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធធន់មាំល្អ (អណ្ដូងជីក អណ្ដូងខួង បង្គន់ សួនបន្លែតាមផ្ទះ) ក្រោយពេលកម្មវិធីអន្តរាគមន៍បានចប់អស់។ ការពិភាក្សាបញ្ចប់ដោយ ការផ្ដល់មតិមួយចំនួន សម្រាប់កម្មវិធីស្ដីពីការប្រែប្រួលអាកាសធាតុនាពេលអនាគត។

## ប្រវត្តិកម្មវិធី

កម្មវិធីសាកល្បងផ្អែកហេដ្ឋារចនាសម្ព័ន្ធធន់ល្អនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានអនុវត្តឡើងក្នុង ៨ភូមិ នៅ ៨ឃុំ (យកមួយភូមិក្នុងមួយឃុំ) ក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ពីឆ្នាំ២០១៥ ដល់ ២០១៩ ដើម្បីកែលំអលទ្ធភាពមានពេញៗមួយឆ្នាំនូវទឹកស្អាត និងប្រព័ន្ធអនាម័យ និងជួយទ្រទ្រង់សមត្ថភាពប្រជាជនក្នុងមូលដ្ឋាន ក្នុងការធ្វើផែនការ និងកសាងជីវភាព អាចធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ។ កម្មវិធីនេះផ្ដោតលើ គ្រួសារក្រីក្រ គ្រួសារមានស្ត្រីជាមេគ្រួ ជនចាស់ជរា គ្រួសារជាទូទៅ ហើយនិងមន្ត្រីរបស់ក្រសួងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (Khim and Chin 2016)។ កម្មវិធីមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់កំណត់អ្នកទទួលផល ដែលមាន ជនក្រីក្រ ជនចាស់ជរា ស្ត្រីជាមេគ្រួសារ ដែលធ្វើការនៅក្នុង ឬនៅជិតភូមិ (ពោលគឺ អ្នកមិនបានធ្វើចំណាកស្រុកដើម្បីទៅបម្រើការងារ) អ្នកមានកម្លាំងពលកម្មគ្រប់គ្រាន់ សម្រាប់ថែទាំសម្ភារបរិក្ខារ អ្នកពេញចិត្តធ្វើសួនបន្លែ និងពេញចិត្តចូលរួម និងបន្តអនុវត្ត ក្រោយពេលជំនួយទ្រទ្រង់ដោយផ្ទាល់បានចប់អស់ទៅ។

ហេដ្ឋារចនាសម្ព័ន្ធធន់នឹងការប្រែប្រួលអាកាសធាតុ ដែលមានផ្ដល់ក្នុងកម្មវិធីនេះ មានសរុប ១១អណ្ដូងជីក ៥អណ្ដូងខួង ៨បង្គន់ និងប្រព័ន្ធប្រមូល/ស្ដុកទឹកភ្លៀង និង ១៦សួនបន្លែតាមផ្ទះ។ បច្ចេកទេសខួង អាចផ្ដល់នូវអណ្ដូងមានជម្រៅជ្រៅជាង មានទឹកពេញៗមួយឆ្នាំ និងគ្មានការបំពុល (រូបភាព១ និង ២)។ បង្គន់ត្រូវបានកសាងនៅលើដីខ្ពស់មិនងាយលិចទឹក នៅក្នុងសាលារៀន និងកន្លែងធ្វើពិធីជាប្រពៃណីផ្សេងៗ ដែលអ្នកភូមិគ្រប់គ្នាអាច

រូបភាព១៖ អណ្ដូងជីក



រូបភាព២៖ អណ្ដូងខួងជម្រៅជ្រៅសម្រាប់ការផ្គត់ផ្គង់ទឹកពេញៗមួយឆ្នាំ



រូបភាព៣៖ បង្គន់និងប្រព័ន្ធប្រមូល/ស្តុកទឹកភ្លៀង សម្រាប់ឲ្យមានអនាម័យល្អ



រូបភាព៤៖ សួនបន្លែមានប្រព័ន្ធស្រោចស្រពតាមដំណក់ទឹក



ប្រើប្រាស់បាន (រូបភាព៣)។ សួនបន្លែបានធ្វើឡើងដោយមានប្រព័ន្ធស្រោចស្រពតាមដំណក់ទឹក (ដើម្បីប្រើទឹកអស់តិច និងងាយថែទាំ) សម្រាប់ការផលិតបន្លែនៅរដូវប្រាំង និងរដូវវស្សា (រូបភាព៤)។

## ការជ្រើសរើសកន្លែងសិក្សា និងការប្រមូលទិន្នន័យ

ភូមិបួន (ក្នុងចំណោមភូមិគោលដៅទាំង ៨ នៃគម្រោងស្រាវជ្រាវ) ក្នុងបួនឃុំ នៅស្រុកកំពង់ស្វាយ ត្រូវបានជ្រើសរើសសម្រាប់ការសិក្សា (រូបភាព៥) ក្នុងនេះ ភូមិបីស្ថិតនៅជិតស្ទឹងសែន (ងាយស្រួលក្នុងការយកទឹក និងធ្វើនេសាទ) ដែលហូរចាក់ទៅបឹងទន្លេសាប រីឯភូមិមួយទៀត ស្ថិតនៅឆ្ងាយពីប្រភពទឹក។ ស្រុកកំពង់ស្វាយទាំងមូល ងាយជួបការរាំងស្ងួត និងកង្វះទឹកធ្ងន់ធ្ងរ។

ទិន្នន័យប្រភពទី១ បានប្រមូលយកពី ១៣សម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ និងការពិភាក្សាតាមក្រុមស្នូល បីលើក (មួយលើកមានពី ៦ ទៅ ១០នាក់) ជាមួយអ្នកទទួលផលពីកម្មវិធី។ ទិន្នន័យប្រភពទី២ បានមកពីទិន្នន័យឃុំឆ្នាំ២០១៨ ជំរឿនឆ្នាំ២០១៩ និងមូលដ្ឋានទិន្នន័យជំរឿនឆ្នាំ២០០៨ (NIS 2018, 2019, 2010)។ អ្នកចូលរួមក្នុងការសិក្សា ត្រូវបានជ្រើសរើសដើម្បីតំណាងឲ្យអ្នកពាក់ព័ន្ធគ្រប់ប្រភេទ គឺមាន គ្រួសារក្រីក្រ គ្រួសារមានស្ត្រីជាមេគ្រួ កុមារ (អាយុក្រោម ១៥ឆ្នាំ) ជនចាស់ជរា (អាយុ ៦៥-៧០ឆ្នាំ) ជនពិការ គ្រួសារទូទៅ អាជ្ញាធរភូមិឃុំ និង បុគ្គលិកបច្ចេកទេសនៃក្រសួងអភិវឌ្ឍន៍ជនបទ។ ទិន្នន័យបានយកមកវិភាគ ដោយប្រើការវិភាគតាមប្រធានបទ។

រូបភាព៥៖ ផែនទីភូមិសិក្សា




ប្រភព៖ ការរៀបចំផែនទីដោយអ្នកនិពន្ធ ផ្អែកលើ NIS 2010

## ស្ថានភាពប្រជាសាស្ត្រនៅកន្លែងសិក្សា

ភូមិទាំងបួនមានប្រជាជនសរុប ៩៣៨គ្រួសារ ត្រូវជា ៤.៦៩៤នាក់ ក្នុងនេះមានពាក់កណ្តាលជាស្រី ៦៧% ស្ថិតក្នុងអាយុបម្រើការងារ (១៥-៦៥ឆ្នាំ) (តារាង១)។ ម្យ៉ាងទៀតមានប្រមាណ ៧៦% ចេះអក្សរ ៥១% បានបញ្ចប់បឋមសិក្សា និង ២១% បានបញ្ចប់មធ្យមសិក្សា (NIS 2018)។ គ្រួសារនានាមានសមាជិកជាមធ្យម បួននាក់ (NIS 2019)។

មុខរបរចម្បងរបស់អ្នកភូមិ គឺ ធ្វើស្រែ។ មានអ្នកភូមិតែមួយភាគតូច (១០%) ប៉ុណ្ណោះ ដែលអាចធ្វើស្រែបានពីរដងក្នុងមួយឆ្នាំ ព្រោះដីស្រែគាត់ ឬមួយមានការស្រោចស្រព ឬមួយស្ថិតនៅជិតប្រឡាយរំដោះទឹក។ ការចិញ្ចឹម មាន់ ជ្រូក គោ ជាប្រភពចំណូលទី២ និងផ្តល់សាច់ហូប។ ម្យ៉ាងទៀត តាមធម្មតាអ្នកភូមិមានដាំបន្លែ និងដើមឈើយកផ្លែ ដូចជា ខ្ទឹម ត្រកួន ចេក ល្ហុង ខ្នុរ ស្វាយ នៅជុំវិញផ្ទះ។ នៅភូមិដំរីស្លាប់ មានប្រមាណ ៣០គ្រួសារ បានធ្វើចំណាកស្រុកទៅធ្វើការនៅថៃពេញមួយឆ្នាំ បើតាមសំដីប្រធានភូមិ។ អ្នកភូមិក៏ពឹងផ្អែកលើការនេសាទ ដើម្បី

តារាង១៖ ភូមិសិក្សានៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

| ឃុំ | ភូមិ | គ្រួសារសរុប | ប្រុសសរុប | ស្រីសរុប |
|---|---|---|---|---|
| កំពង់គោ | បួពឹង | 192 | 449 | 468 |
| ដំរីស្លាប់ | ដំរីស្លាប់ | 181 | 391 | 394 |
| ត្រពាំងឫស្សី | ល្វាដោម | 230 | 640 | 565 |
| ក្តីដូង | ពាមគ្រែង | 335 | 873 | 914 |
| **សរុប** | | **938** | **2,353** | **2,341** |

ប្រភព៖ (NIS, 2018)

ទ្រទ្រង់ សន្តិសុខស្បៀងក្នុងគ្រួសារដែរ។ អ្នកភូមិមិនមានការតភ្ជាប់នឹងបណ្ដាញផ្គត់ផ្គង់អគ្គិសនីទេ។ អាគុយរថយន្ត (៦៦%) និងផ្ទាំងសូឡា ជាប្រភពទូទៅនៃថាមពលសម្រាប់បំភ្លឺ ហើយគេប្រើអុសជាទូទៅ សម្រាប់ចម្អិនអាហារ (NIS 2018)។ គ្រួសារប្រមាណ ៥០% មានបង្គន់តាមផ្ទះ។

## លទ្ធផលរកឃើញ៖ កត្តាសំខាន់ៗរារាំងការសម្រេចបានអត្ថប្រយោជន៍

អ្នកចូលរួមក្នុងការសិក្សា បានបញ្ជាក់ពីការពេញចិត្តលើកម្មវិធីសាកល្បង ហើយសំណូមពរឲ្យពង្រីកវាទៅគ្រប់ភូមិនៅក្នុងខេត្ត។ សួនបន្លែតាមផ្ទះបានទទួលអត្ថប្រយោជន៍ពីស្ត្រីនិងកុមារ ពីព្រោះអ្នកទាំងនេះមានពេលច្រើននៅផ្ទះ ហើយអាចថែទាំសួន។ ប៉ុន្តែការសិក្សាបានរកឃើញ កត្តារារាំងបួនដែលប៉ះពាល់ដល់ការចូលរួមរបស់អ្នកទទួលផល៖ ធាតុអាកាសក្ដៅពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ រចនាសម្ព័ន្ធ/សមត្ថភាពគ្រួសារ (ការផ្គត់ផ្គង់ពលកម្ម និងហិរញ្ញវត្ថុក្នុងគ្រួសារ) ការជួសជុលសម្ភារបរិក្ខារខូច ឬមានបញ្ហា (ពឹងផ្អែកលើជំនួយបច្ចេកទេសពីរដ្ឋាភិបាល) និងយុទ្ធសាស្ត្រចិញ្ចឹមជីវិត និងអាទិភាពរបស់គ្រួសារក្រីក្រ។ កត្តាទាំងនេះមានលំអិតនៅខាងក្រោម៖

### *សីតុណ្ហភាពក្ដៅពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ*

ការថែទាំសួនបន្លែតាមផ្ទះ បានជួបបញ្ហាប្រឈមដោយសារធាតុអាកាសក្ដៅខ្លាំងណាស់ យោងតាមសំដីមន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទខេត្តម្នាក់។ នៅពេលមានរលកកំដៅនៅខែឧសភា ២០១៩ សីតុណ្ហភាពឡើងដល់ ៤២អង្សាសេ ធៀបនឹង សីតុណ្ហភាពប្រចាំខែមធ្យមត្រឹម ៣០អង្សាសេ និងឡើងដល់ ៣៤អង្សាសេម្ដងម្កាល។ ទឹកសឹងតែខ្វះខាតជានិច្ចនៅរដូវប្រាំង ពីព្រោះអណ្ដូងភាគច្រើន រាប់ទាំងអណ្ដូងជ្រៅៗផង រីងទឹកអស់។ អ្នកភូមិរាយការណ៍ថា រដូវភ្លៀងមកដល់កាន់តែយឺតយ៉ាវ ហើយខែមិថុនា និងកក្កដា ដែលពីដើមរៀងមកជាខែភ្លៀង ឥឡូវនេះនៅរាំងស្ងួតទាំងស្រុង។ ប្រធានភូមិម្នាក់និយាយថា៖

> គម្រោងអភិវឌ្ឍន៍របស់ក្រសួងអភិវឌ្ឍន៍ជនបទ បានជួយកែលំអស្ថានភាពអនាម័យ។ ប៉ុន្តែអណ្ដូងថ្មីៗដោះស្រាយកង្វះទឹកបានតែមួយភាគប៉ុណ្ណោះ ពីព្រោះគម្រោងបានផ្ដល់តែ ៨អណ្ដូង ហើយអ្នកភូមិកសាងបានតែ ១៣អណ្ដូងទៀត។ ដើម្បីដោះស្រាយបញ្ហានេះ ប្រជាជនទិញទឹកពីអ្នកផ្គត់ផ្គង់ឯកជនក្នុងថ្លៃ ១៣.០០០រៀល សម្រាប់ទឹកមួយធុងចំណុះ ៥.០០០លីត្រ។ អ្នកភូមិសឹង ១០០% ប្រើអណ្ដូង [ជាប្រភពទឹកចម្បង]។

> តាមសំដីបុគ្គលិកក្រសួងអភិវឌ្ឍន៍ជនបទ៖
> ការជីក និងស្ដារជួសជុលស្រះទឹកឲ្យបានច្រើនទៀត អាចជួយស្តុកទឹកបានកាន់តែច្រើន សម្រាប់ការប្រើប្រាស់ក្នុងឃុំនៅរដូវប្រាំង។

### *រចនាសម្ព័ន្ធ/សមត្ថភាពគ្រួសារ (មានកម្លាំងពលកម្ម និងលទ្ធភាពរកបានហិរញ្ញវត្ថុ)*

គម្រោងសាកល្បង ដែលផ្ដល់សួនបន្លែតាមផ្ទះឲ្យគ្រួសារក្រីក្រ និងគ្រួសារជនចាស់ជរា គឺមានជោគជ័យកម្រិតទាបត្រឹម ៣០% ទៅ ៤០% ពីព្រោះការថែទាំសួនបន្លែតាមផ្ទះ (ថែទាំកូនបន្លែ ស្រោចទឹក ដកស្មៅ បំពេញធុងទឹក ធ្វើជីកំប៉ុស្ដ ...) មានការងារហត្ថកម្មច្រើនគួរសម ដូច្នេះត្រូវមានកម្លាំងកាយក្នុងកម្រិតណាមួយ។ ដោយមូលហេតុនេះ គ្រួសារមានជនពិការ និង/ឬ ជនចាស់ជរា ឬគ្រួសារពុំមានកម្លាំងពលកម្មគ្រប់គ្រាន់ អាចជួបបញ្ហាប្រឈមក្នុងការគ្រប់គ្រងសួនបន្លែតាមផ្ទះ។

> តាមសំដីស្ត្រីម្ចាស់ផ្ទះម្នាក់នៅភូមិដំរីស្លាប់៖
> ខ្ញុំទទួលបានសួនបន្លែតាមផ្ទះមួយ ពីគម្រោងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ហើយខ្ញុំជួបបញ្ហាប្រឈមមួយចំនួន។ ទី១ ទាំងប្ដីខ្ញុំនិងរូបខ្ញុំ គឺកាន់តែចាស់ ហើយមិនមានកម្លាំងគ្រប់គ្រាន់សម្រាប់ដាំបន្លែទេ តាំងពីមុនពេលគម្រោងបានចាប់ផ្ដើមម្លេះ។ ដាំបន្លែ ជាការងារនឿយហត់គួរសម។ យើងខ្ញុំ បានដាំបន្លែក្នុងសួនតាមផ្ទះនេះពីរលើកមកហើយ ប៉ុន្តែគួរឲ្យស្ដាយដំណាំទាំងអស់បានខូចខាត ហើយយើងខ្ញុំមិនដឹងថា វាយ៉ាងម៉េច និងមកពីហេតុអ្វីទេ ទោះបីបានធ្វើតាម ការណែនាំក្នុងពេលបណ្ដុះបណ្ដាលនោះហើយក្ដី។ នៅពេលបុគ្គលិកគម្រោងចុះមកមើល ខ្ញុំបានប្រាប់គាត់តាមការពិត និងសុំឲ្យគាត់យកសួនតាមផ្ទះនេះទៅឲ្យគ្រួសារផ្សេងដែលមានកម្លាំងដាំបន្លែវិញ។

ប្រព័ន្ធស្រោចស្រពប្រើដំណក់ទឹក សម្រាប់ស្រោចសួនបន្លែតាមផ្ទះក្នុងគម្រោងសាកល្បងនេះ វាមានតម្លៃខ្ពស់ដែលអាចជាបញ្ហាប្រឈមសម្រាប់សហគមន៍ ដើម្បីកសាងវានៅតាមភូមិផ្សេងៗទៀត។ ប៉ុន្តែបុគ្គលិកក្រសួងអភិវឌ្ឍន៍ជនបទបានផ្ដល់មតិថា អ្នកភូមិអាចប្រើធនធានក្នុងមូលដ្ឋាន ដូចជា បង្គោលឈើជាដើម ជាជាងទៅទិញសម្ភារបរិក្ខារថ្លៃៗ។

### *ជំនួយបច្ចេកទេសពីរដ្ឋាភិបាល*

ប្រជាជនភាគច្រើនដែលរស់នៅក្នុងគ្រួសារក្រីក្រ តែងមានកម្រិតអប់រំទាប មានជំនាញធ្វើការកម្រិតទាប ឬគ្មានសោះ និងត្រូវការជំនួយហិរញ្ញវត្ថុ។ នៅកម្រិតទាបបំផុត គ្រួសារក្រីក្រជាងគេត្រូវការជាប់រហូត និងដោយផ្ទាល់ នូវជំនួយកម្រិតគ្រួសារ ដើម្បីកែលំអស្ថានភាពខ្លួន។ អ្នកភូមិខ្លះមានតម្រូវការច្បាស់ទៃងនូវសមត្ថភាព ជួសជុលអណ្ដូងខូច គ្រប់គ្រងសួនបន្លែតាមផ្ទះ និងធ្វើផែនការថវិកាសម្រាប់ទិញគ្រឿងបន្លាស់។ ទោះបីមានការបង្កើតគណៈកម្មាធិការភូមិ (ឃុំមួយមានគណៈកម្មាធិការនេះមួយ) ដើម្បីថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធក្ដី ក៏ការថែទាំបានជួបឧបសគ្គដោយសារកង្វះខាតចំណេះធ្វើ និងបន្ទុកចំណាយជាប់ទាក់ទិន។

យោងតាម ការពិភាក្សាតាមក្រុមស្នូល ជាមួយសមាជិកក្រុមប្រឹក្សាឃុំ នៅឃុំសាន់គះ

អណ្ដូងនៅឆ្ងាយពីផ្ទះ។ អ្នកភូមិខ្លះប្រើវា ប៉ុន្តែមិនព្រមថែទាំវាទេ។ "ការលំបាកក្នុងគម្រោង រួមមាន អណ្ដូងខូចគ្មានគ្រឿងបន្លាស់ និងគ្មានអ្នកណាអាចជួសជុលវាបាន" យោងតាមសំដីមេឃុំនៅឃុំសាន់គ។

ការថែទាំ អណ្ដូង បង្គន់ ប្រព័ន្ធប្រមូលនិងស្ដុកទឹក និង សួនបន្លែតាមផ្ទះ គឺជាបញ្ហាប្រឈមចម្បង ហើយសកម្មភាពថែទាំទាំងនេះត្រូវមានសហប្រតិបត្តិការពី អ្នកទទួលផល អ្នកប្រើប្រាស់ឯទៀតៗ និងអាជ្ញាធរក្នុងមូលដ្ឋាន។

## *យុទ្ធសាស្ត្រចិញ្ចឹមជីវិតរបស់គ្រួសារក្រីក្រ និងក្រីក្រខ្លាំង (អាទិភាពខុសៗគ្នា)*

គ្រួសារក្រីក្រតាមធម្មតាផ្ដល់អាទិភាពដល់ ប្រាក់ចំណូលបានពីការងារមានប្រាក់ឈ្នួល។ គ្រួសារខ្លះបានចាកចេញពីភូមិខ្លួនទៅរកការងារនៅកន្លែងផ្សេង ដែលផ្ទុយពីលក្ខណៈវិនិច្ឆ័យ "ត្រូវធ្វើការនៅក្នុង ឬនៅជិតភូមិ" សម្រាប់ជ្រើសរើសអ្នកទទួលផលដែលសាកសមនឹងកម្មវិធី។ គ្រួសារខ្លះទៀតបានបាត់បង់ការប្ដេជ្ញាចិត្ត ហើយបានផ្ដល់អាទិភាពដល់ប្រាក់កម្រៃប្រចាំថ្ងៃដោយបម្រើការជាអ្នកស៊ីឈ្នួលធ្វើស្រែវិញ។ សួនបន្លែតាមផ្ទះពិតជាដំណើរការមិនបានល្អទេ សម្រាប់គ្រួសារក្រីក្រ។ ផ្ទុយទៅវិញ គ្រួសារមធ្យម និងគ្រួសារធូរធារ មានកម្លាំងពលកម្មច្រើនជាង និងប្រភពចំណូលច្រើនមុខជាង ដូច្នេះគាត់មានមធ្យោបាយបង្កើត និងគ្រប់គ្រងសួនបន្លែតាមផ្ទះបានជោគជ័យ។

យោងតាមមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទម្នាក់៖

> មានហេតុផលជាច្រើនបង្ហាញថា ហេតុអ្វីបានជាអ្នកភូមិ[ខ្លះ]បានបរាជ័យក្នុងការធ្វើសួនបន្លែតាមផ្ទះ។ ពួកគាត់គិតថា សួនបន្លែតាមផ្ទះជាប្រភពចំណូលទី២ ឬទី៣ គឺមិនមែនជាប្រភពចម្បងទេ។ ពួកគាត់មានជម្រើសផ្សេងទៀត ដើម្បីបានប្រាក់ចំណូលខ្ពស់ជាងនេះច្រើនណាស់ គឺពី ការងារបានប្រាក់ឈ្នួល ការងារក្នុងរោងចក្រកាត់ដេរនៅទីក្រុង ឬការងារនៅក្នុងព្រៃ។ ដូច្នេះគាត់គ្មានការចាំបាច់អ្វី នឹងថែទាំសួនបន្លែតាមផ្ទះនោះទេ ព្រោះគាត់អាចរស់បានដោយគ្មានវា។

> យោងតាមអភិបាលស្រុកកំពង់ស្វាយ៖
> "អាទិភាពខ្ពស់បំផុតសម្រាប់សហគមន៍នានាក្នុងស្រុកនេះ គឺស្ដារជួសជុលផ្លូវតាមដងប្រឡាយ៣០កញ្ញា ពីព្រោះវាជាផ្លូវចម្បង សម្រាប់ដឹកជញ្ជូនស្រូវអង្ករទៅទីផ្សារ ហើយវាផ្ដល់អត្ថប្រយោជន៍ដល់ស្រុកទាំងមូលផង"

## សេចក្ដីសន្និដ្ឋាន

អ្នកទទួលផល ពីកម្មវិធីអន្តរាគមន៍លើការប្រែប្រួលអាកាសធាតុនៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ បានបញ្ជាក់ប្រាប់ពីការគាំទ្ររបស់គាត់ដល់កម្មវិធី ហើយបានសំណូមពរថា ការផ្ដល់ អណ្ដូង បង្គន់ សួនបន្លែតាមផ្ទះ និង ប្រព័ន្ធប្រមូលនិងស្ដុកទឹកភ្លៀង គួរពង្រីកបន្ថែមក្នុងខេត្តទាំងមូល។ ប៉ុន្តែទិដ្ឋភាពខ្លះនៃកម្មវិធីដំណើរការមិនបានល្អដូចការគិតទុកទេ ព្រោះអត្ថប្រយោជន៍ដែលគេចង់បាន គេមិនអាចសម្រេចវាបានពេញលេញ។ ការសិក្សានេះរកឃើញថា មានកត្តាបួនដែលរារាំងលទ្ធភាពរបស់គ្រួសារក្រីក្រ ដើម្បីទទួលបានអត្ថប្រយោជន៍ពេញលេញពីកម្មវិធីអន្តរាគមន៍ ពោលគឺ កង្វះកម្លាំងពលកម្មក្នុងគ្រួសារជនចាស់ជរា កំដៅខ្លាំងពេក អាទិភាពខុសគ្នា/ការបាត់បង់ការប្ដេជ្ញាចិត្ត ក្នុងចំណោមគ្រួសារក្រីក្រ និងកង្វះចំណេះធ្វើផ្នែកបច្ចេកទេសនិងជំនួយគាំទ្រជាហិរញ្ញវត្ថុ។

លទ្ធផលរកឃើញបង្ហាញថា អន្តរាគមន៍ផ្សេងៗទៅអនាគត ដើម្បីកសាងសមត្ថភាពបន្សាំរបស់ ប្រជាជនរស់នៅក្នុងភាពក្រីក្រ និងក្រុមងាយរងគ្រោះផ្សេងទៀត ឲ្យចេះកសាងយុទ្ធសាស្ត្រចិញ្ចឹមជីវិតធន់នឹងការប្រែប្រួលអាកាសធាតុ គឺគួរពិចារណាលើចំណុចដូចតទៅ៖

១. ហេដ្ឋារចនាសម្ព័ន្ធធន់នឹងការប្រែប្រួលអាកាសធាតុ៖ ការបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុ នៃផ្លូវនានាដែលជួយឲ្យប្រជាជនក្នុងមូលដ្ឋាន អាចទៅដល់កន្លែងគាត់ចង់ទៅ និងការបង្កើនលទ្ធភាពមានប្រភពទឹកកាន់តែប្រសើរ គឺជាធាតុផ្សំគន្លឹះពីរ។ ការជីកស្រះឲ្យបានច្រើនថែមទៀតសម្រាប់ស្ដុកទឹកទុកប្រើនៅរដូវប្រាំង ក៏ជាអាទិភាពមួយដែរ ពីព្រោះអណ្ដូងភាគច្រើនត្រូវរីងស្ងួតអស់។ ការស្ដារជួសជុលផ្លូវតាមដងប្រឡាយ៣០កញ្ញា នៅស្រុកកំពង់ស្វាយ នឹងជួយបង្កើនស្ថិរភាពក្នុងជីវភាពរស់នៅ ពីព្រោះវាជាផ្លូវចម្បងសម្រាប់ដឹកជញ្ជូនស្រូវអង្ករទៅទីផ្សារ។

២. ជម្រើសចិញ្ចឹមជីវិតមានច្រើនមុខ៖ ដោយសារគ្រួសារក្រីក្រផ្ដល់អាទិភាពខ្ពស់ដល់ការងារមានប្រាក់ឈ្នួល រួមទាំងការធ្វើចំណាកស្រុកទៅរកការងារធ្វើផង អន្តរាគមន៍បន្សាំនឹងការប្រែប្រួលអាកាសធាតុផ្សេងៗ គួរមានជួយបង្កើតជម្រើសច្រើននូវការងារផ្ដល់ប្រាក់ឈ្នួលមានចីរភាព សម្រាប់គ្រួសារក្រីក្រនៅក្នុងសហគមន៍។

៣. ការបណ្ដុះបណ្ដាលពីការថែទាំសម្ភារបរិក្ខារ៖ ប្រជាជនក្នុងមូលដ្ឋាន ដែលទទួលផលពីគម្រោង និងគណៈកម្មការថែទាំ គួរនៅតែទទួលបានការបណ្ដុះបណ្ដាល ពីរបៀបថែទាំជួសជុលសម្ភារបរិក្ខារ និងសំណង់ផ្សេងៗ ដែលគម្រោងបានផ្ដល់ឲ្យ មានជាអាទិ៍ អណ្ដូង/ម៉ាស៊ីនបូមទឹក សួនបន្លែតាមផ្ទះ ប្រព័ន្ធប្រមូលនិងស្ដុកទឹកភ្លៀង។ វិធីនេះអាចជួយកាត់បន្ថយការពឹងផ្អែកលើជំនួយបច្ចេកទេស ពីក្រសួងអភិវឌ្ឍន៍ជនបទ និងជួយឲ្យឃុំកាន់តែមានភាពឯករាជ្យក្នុងពេលអនុវត្តគម្រោង។ ការធ្វើផែនការថវិកាសម្រាប់ទិញគ្រឿងបន្លាស់ ដោយមានជំនួយហិរញ្ញវត្ថុពីរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសហគមន៍ផង គួរតែអនុវត្តឲ្យបាន។

## ឯកសារយោង

Anshory Yusuf, A., & Francisco, H. (2009). *Climate Change Vulnerability Mapping for Southeast Asia.* Economy and Environment Program for Southeast Asia (EEPSEA). Singapore. http://www.eepsea.org

CDRI, MRD, UNDP (2019). *Impact of Climate Change Programs in Cambodia: Vulnerability, Poverty, and*

*តទៅទំព័រ ១៨*

*តពីទំព័រ ៥* **កត្តាពរាំង...**

*Gender. Research Finding 2019.* CDRI *(unpublished, due in May 2021)*

Khim, Phearum & Chin, Samphors. (2016). *Climate-Proofing Integration Rural Community Development.* Ministry of Rural Development. Phnom Penh, Cambodia

Khoday, Kishan ; Ali, W. (n.d.). Climate Change and the Rise of Poverty | UNDP. Retrieved September 23, 2020, from https://www.undp.org/content/undp/en/home/blog/2018/Climate_Change_and_the_Rise_of_Poverty.html

Nang, P., & Chhuong, O. (2014). *Gender and Water Governance: Women's Role in Irrigation Management and Development in the Context of Climate Change.* CDRI Working Paper Series No. 89

National Institute of Statistics (NIS). (2010). 2008 *census map layers and databases.* Phnom Penh: National Institute of Statistics.

NCDM. (2020). Cambodia Disaster Damage & Loss Information System: Kampong Thom Province. Retrieved August 3, 2020, from http://camdi.ncdm.gov.kh/DesInventar/profiletab.jsp

NIS. (2018). *Commune database 2018.* Phnom Penh, Cambodia.

NIS (Nation Institute of Statistics of the Ministry of Planning). (2019). *General Population Census of the Kingdom of Cambodia 2019: Provisional Population Totals.*

Nyahunda, L., & Tirivangasi, H. M. (2019). Challenges faced by rural people in mitigating the effects of climate change in the Mazungunye communal lands, Zimbabwe. *Jàmbá Journal of Disaster Risk Studies, 11*(1), 1–9. https://doi.org/10.4102/jamba.v11i1.596

Anshory Yusuf, A., & Francisco, H. (2009). *Climate Change Vulnerability Mapping for Southeast Asia.* Economy and Environment Program for Southeast Asia (EEPSEA). Singapore. http://www.eepsea.org

CDRI, MRD, UNDP (2019). *Impact of Climate Change Programs in Cambodia: Vulnerability, Poverty, and Gender. Research Finding 2019. CDRI (unpublished, due in May 2021)*

Khim, Phearum & Chin, Samphors. (2016). *Climate-Proofing Integration Rural Community Development.* Ministry of Rural Development. Phnom Penh, Cambodia

Khoday, Kishan ; Ali, W. (n.d.). Climate Change and the Rise of Poverty | UNDP. Retrieved September 23, 2020, from https://www.undp.org/content/undp/en/home/blog/2018/Climate_Change_and_the_Rise_of_Poverty.html

Nang, P., & Chhuong, O. (2014). *Gender and Water Governance: Women's Role in Irrigation Management and Development in the Context of Climate Change.* CDRI Working Paper Series No. 89

National Institute of Statistics (NIS). (2010). 2008 *census map layers and databases.* Phnom Penh: National Institute of Statistics.

NCDM. (2020). Cambodia Disaster Damage & Loss Information System: Kampong Thom Province. Retrieved August 3, 2020, from http://camdi.ncdm.gov.kh/DesInventar/profiletab.jsp

NIS. (2018). *Commune database 2018.* Phnom Penh, Cambodia.

NIS (Nation Insitute of Statistics of the Ministry of Planning). (2019). *General Population Census of the Kingdom of Cambodia 2019: Provisional Population Totals.*

Nyahunda, L., & Tirivangasi, H. M. (2019). Challenges faced by rural people in mitigating the effects of climate change in the Mazungunye communal lands, Zimbabwe. *Jàmbá Journal of Disaster Risk Studies,* 11(1), 1–9. https://doi.org/10.4102/jamba.v11i1.596

*តពីទំព័រ ២៤* **ព័ត៌មានថ្មីៗ...**

អ្នកគ្រប់គ្រងមួយចំនួននៃ AGID និង នាយកនិងបុគ្គលិកជាច្រើននៃ CDRI ក៏បានចូលរួមក្នុងពិធីចុះហត្ថលេខានេះដែរ។

នាឱកាសនោះ លោក ចាន់ សុភក្ដិ បានចែករំលែកបទពិសោធន៍បានពីគម្រោងការរបស់ AGID លើការធ្វើកសិកម្មតាមកិច្ចសន្យាការនាំចេញផ្លែស្វាយទៅជប៉ុន គំនិតផ្ដួចផ្ដើមធ្វើយន្ដកម្មកសិកម្ម និងនវានុវត្តន៍ក្នុងអាជីវកម្មផ្នែកកសិកម្ម។

**ជំនួបជាមួយ គណៈកម្មាធិការសម្រាប់លើកកម្ពស់ផលិតភាពនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

នៅថ្ងៃទី១៨ ឧសភា CDRI បានទទួលស្វាគមន៍ គណៈប្រតិភូមួយរបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការផលិតភាពជាតិ ដែលដឹកនាំដោយ ឯ.ឧ ស៊ីសុវត្ថិ ដួង ចាន់តូ ជាអគ្គលេខាធិការ។ CDRI មានកត្តិយសដោយបានចូលរួមក្នុងវេទិកាដ៏សំខាន់នេះ ដើម្បីជួយជំរុញកំណើនផលិតភាពនៅកម្ពុជា គុណភាពអភិបាលកិច្ច សមត្ថភាពធនធានមនុស្ស (ចំណេះដឹង ជំនាញ ឥរិយាបទ) នវានុវត្តន៍ និងការអភិវឌ្ឍបច្ចេកវិទ្យា។ ដោយសារ CDRI មានឋានៈជា វិទ្យាស្ថានស្រាវជ្រាវ ផ្នែកគោលនយោបាយអភិវឌ្ឍឯករាជ្យ និងឈានមុខគេនៅកម្ពុជា ឯ.ឧ អគ្គលេខាធិការ បានលើកមតិថា CDRI និង គណៈកម្មាធិការជាតិសម្រាប់សេដ្ឋកិច្ចមានផលិតភាពនៅកម្ពុជា (NCCPE) គួររួមសហការគ្នាឲ្យបានច្រើន ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមានផលិតភាពនៅកម្ពុជា។ នាយកប្រតិបត្តិនៃ CDRI បានទទួលស្វាគមន៍មតិនេះ ហើយត្រៀមចូលរួមសហការឲ្យមានផ្លែផ្កា។

**ទស្សនកិច្ចរបស់ ឯ.ឧ ទាន សំណាង ប្រធានវិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**

នៅថ្ងៃទី២១ ឧសភា ឯ.ឧ ទាន សំណាង ប្រធានវិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិ (NIDIR) បានជួបជាមួយតំណាងវិទ្យាស្ថាន CDRI រួមមាន នាយកប្រតិបត្តិ នាយកស្រាវជ្រាវ នាយកមជ្ឈមណ្ឌលសម្រាប់ធនធានធម្មជាតិនិងបរិស្ថាន និង នាយកមជ្ឈមណ្ឌលស្រាវជ្រាវគោលនយោបាយកសិកម្ម និងអភិវឌ្ឍន៍ជនបទ ដើម្បីពិភាក្សា និងពង្រឹងសហប្រតិបត្តិការរវាងវិទ្យាស្ថានទាំងពីរ។ គណៈប្រតិភូ NIDIR រួមមាន លោក ចាន់ ប៊ុណ្ណារិទ្ធិ ប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ និង បណ្ឌិត ផុន សុខបញ្ញា ជាជំនួយការ។

**ឯ.ឧ អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានជួបជាមួយ ថ្នាក់ដឹកនាំ និងអ្នកស្រាវជ្រាវ CDRI**

នៅថ្ងៃទី២៦ ឧសភា ឯ.ឧ អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន បានទទួលស្វាគមន៍គណៈប្រតិភូ CDRI រួមមាន នាយកប្រតិបត្តិ នាយកស្រាវជ្រាវ នាយកមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ចនិង